# សុយោនន្ទីជាតក

## (ព្រះត្រៃបិដកខ្មែរថា សុសន្ធីជាតក)



*ព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧក្កណ្ឋិតភិក្ខុ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **វាតិ គន្ធោ តិមិរានំ** *ដូច្នេះជាដើម ។*

*ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតមែនឬ ? ភិក្ខុនោះទូលថា ពិតមែនហើយ ព្រះអង្គ ។ ព្រះពុទ្ធទើបត្រាស់ថា អ្នកឃើញអ្វី (បានជាអផ្សុក) ? លោកឆ្លើយថា ព្រោះបានឃើញមាតុគ្រាមដែលប្រដាប់តាក់តែងខ្លួន ។ ព្រះទសពលត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា មាតុគ្រាម នេះ អ្នកណាៗមិនអាចនឹងរក្សាបាន បោរាណបណ្ឌិតទាំងឡាយសូម្បីធ្វើការរក្សាក្នុងសុបណ្ណពិភព (ឋានគ្រុឌ) ហើយ ក៏មិនអាចនឹងរក្សាបានដែរ។ ព្រះភគវាដែលភិក្ខុនោះទូលអារាធនាហើយ ទើបទ្រង់នាំអតីតនិទានមកសម្តែងថា*

**អតីតេ** *ក្នុងអតីតកាលដ៏យូរលង់ណាស់មកហើយ ព្រះរាជាព្រះនាម* **តម្ពរាជា** *សោយរាជ្យក្នុងនគរពារាណសី ។ ព្រះអគ្គមហេសីរបស់ព្រះរាជានោះ មានព្រះនាមថា* **សុយោនន្ទី**

ព្រះនាងទ្រទ្រង់ព្រះរូបឆោមដ៏ឧត្តម ។ ក្នុងគ្រានោះ ព្រះពោធិសត្វកើតក្នុងកំណើតជាសត្វគ្រុឌ ក្នុងកាលនោះ **នាគទ្វីប** មានឈ្មោះថា **សេទុមទ្វីប** ។ ព្រះពោធិសត្វនៅក្នុងសុវណ្ណពិភពលើទ្វីបនោះ ។ ព្រះអង្គយាងទៅនគរពារាណសី ហើយលែងបាសកាដោយភេទជាមាណពជាមួយនឹងព្រះបាទតម្ពរាជនោះ ។ ស្ត្រីជាបរិចារិកាឃើញរូបសម្បត្តិរបស់ព្រះពោធិសត្វនោះហើយ បានប្រាប់ដល់ព្រះនាងសុយោនន្ទីថា មាណពដែលឈ្មោះយ៉ាងនេះលេងបាស្កាជាមួយនឹងព្រះរាជារបស់ពួកយើង ។ ព្រះនាងសុយោនន្ទីនោះ បានស្តាប់ហើយ ក៏មានសេចក្តីប្រាថ្នាចង់ឃើញមាណពនោះ ។ ថ្ងៃមួយ ព្រះនាងប្រដាប់តាក់តែងខ្លួនហើយ យាងមកកាន់ស្ថានទីលេងបាសកា ទ្រង់បិតនៅក្នុងចន្លោះនៃស្ត្រីបរិចារិកា រួចលបលួចសម្លឹងមើលមាណពនោះ ។ សូម្បីមាណពនោះក៏សម្លឹងមើលព្រះទេវីវិញដែរ ។ ជនទាំងពីរនាក់ក៏មានចិត្តប្រតិព័ទ្ធ ចាប់ចិត្តស្រឡាញ់ ស្នេហានូវគ្នានឹងគ្នា ។ (ក្នុងពេលនោះ) ស្តេចគ្រុឌពោធិសត្វបានញុំាងខ្យល់ឲ្យតាំងឡើងក្នុងនគរ ដោយអានុភាពរបស់ខ្លួន មនុស្សទាំងឡាយនាំគ្នាចេញអំពីរាជនិវេសន៍ដោយសេចក្តីភ័យខ្លាចផ្ទះបាក់រលំ ។ ស្តេចគ្រុឌនោះ បានធ្វើភាពងងឹតអន្ធការដោយអានុភាពរបស់ខ្លួនហើយ ទើបចាប់ព្រះទេវី រួចមកតាមអាកាស ចូលកាន់ពិភពរបស់ខ្លួន ដែលនៅលើនាគទ្វីបនោះ ។ ឈ្មោះថា អ្នកដែលស្គាល់ស្ថានទី ដែលព្រះនាងសុយោនន្ទីយាងទៅ រមែងមិនមាន ។ ស្តេចគ្រុឌពោធិសត្វនោះ បានអភិរម្យមួយអន្លើដោយព្រះនាងសុយោនន្ទី រួចហើយទើបយាងទៅនគរពារាណសី នឹងលេងបាស្កាជាមួយនឹងព្រះរាជាតម្ពៈនោះ (ដូចធម្មតា) ។

ចំណែកព្រះបាទតម្ពរាជាមានគន្ធព្វ ឈ្មោះ **សគ្គៈ** ។ ព្រះអង្គមិនជ្រាបស្ថានទីដែលព្រះទេវីយាងទៅ ទើបហៅគន្ធព្វនោះមកហើយ ទ្រង់ត្រាស់ថា ម្នាលគន្ធព្វ អ្នកចូរទៅ ចូរត្រាច់ទៅតាមផ្លូវគោក និងផ្លូវទឹក ហើយស្វែងរកស្ថានទីដែលព្រះទេវីយាងទៅ ដូចនេះហើយក៏បញ្ជូនគន្ធព្វនោះទៅ ។ គន្ធព្វនោះកាន់យកស្នៀង ហើយចេញចាកទ្វារស្រុក ត្រាច់ទៅរហូតដល់កំពង់មួយឈ្មោះ **កុរុកច្ឆៈ** ។ ក្នុងគ្រានោះ ពួកពាណិជដែលរស់នៅកំពង់កុរុកច្ឆៈបាននាំគ្នាធ្វើដំណើរទៅកាន់សុវណ្ណភូមិដោយនាវា ។ គន្ធព្វនោះក៏ចូលទៅរកពាណិជទាំង

នោះ ហើយពោលថា ខ្ញុំជាគន្ធព្វ (អ្នករបាំ) នឹងបែងចែងថ្លៃឈ្នួលដល់នាវា ហើយធ្វើនូវការដេញពិណនិងច្រៀងដល់ពួកលោក សូមពួកលោកចូរនាំខ្ញុំទៅផង ។ ពួកពាណិជទាំងនោះទទួលថា ល្អ ហើយឲ្យគន្ធព្វនោះឡើងលើនាវា រួចទើបចេញទៅ ។ កាលនាវាកំពុងបរទៅយ៉ាងសុខស្រួល ពាណិជទាំងនោះក៏ហៅគន្ធព្វមកហើយពោលថា លោកចូរដេញពិណនិងច្រៀងដល់ពួកយើង ។ គន្ធព្វពោលថា ប្រសិនបើខ្ញុំនឹងធ្វើការដេញពិណនិងច្រៀង ក្នុងកាលដែលខ្ញុំកំពុងដេញពិណនិងច្រៀងនោះ ត្រីទាំងឡាយនឹងចលាចល លំដាប់នោះ នាវារបស់ពួកលោកនឹងបែកធ្លាយ ។ ពួកពាណិជពោលថា កាលធ្វើការដេញពិណនិងច្រៀងឲ្យល្មមប្រមាណត្រឹមតែពួកមនុស្ស ឈ្មោះថា ការចលាចលនៃហ្វូងត្រីទាំងឡាយ រមែងមិនមាន លោកចូរធ្វើការដេញពិណនិងច្រៀងចុះ ។ គន្ធព្វពោលថា បើយ៉ាងនោះ លោកទាំងឡាយកុំខឹងនឹងខ្ញុំ ដូច្នេះហើយ ទើបស្រាយនូវពិណរួចធ្វើនូវការដេញពិណនិងច្រៀង មិនឲ្យកន្ទងសំឡេងច្រៀងដោយសំឡេងពិណ មិនឲ្យកន្ទងសំឡេងពិណដោយសំឡេងច្រៀង ។ ត្រីទាំងឡាយរំភើបស្រើបស្រាល អណ្តែតអណ្តូងដោយសំឡេងនោះ ទើបនាំគ្នាចលាចល ។

លំដាប់នោះ មានមករមួយ (ឈ្មោះត្រីសមុទ្រមួយប្រភេទ មានខ្លួនធំ ក្បាលខ្លីក្រមុប ធ្មេញនិងចង្កូមស្វាញគួរស្ញើម; ខ្មែរហៅសំដៅ ត្រីថ្កុរ ក៏មាន, ច្រើននិយាយថា ឆ្លាមមករ) លោតឡើង ហើយធ្លាក់ចុះលើនាវា បានញ៉ាំងនាវាឲ្យបែក ។ សគ្គគន្ធព្វបានដេកលើបន្ទះក្តារ រសាត់អណ្តែតទៅតាមខ្យល់ រហូតដល់ដើមជ្រៃមួយដែលជាពិភពគ្រុឌ លើនាគទ្វីបនោះ ។ ចំណែកព្រះនាងសុយោនន្ទីទេវី ក្នុងវេលាដែលស្តេចគ្រុឌទៅលេងបាស្កាជាមួយព្រះរាជា ក៏ចុះចាកវិមាន ត្រាច់យាងតាមឆ្នេរសមុទ្រ បានឃើញសគ្គគន្ធព្វហើយទ្រង់ចាំបាន ទើបសួរថា លោកមក បានយ៉ាងណា ? គន្ធព្វនោះ ក៏ពោលប្រាប់រឿងរ៉ាវទាំងអស់ ។ ព្រះនាងសុយោនន្ទី លួងលោមគន្ធព្វនោះថា បើយ៉ាងនោះ លោកកុំភ័យឡើយ ដូច្នេះហើយ ព្រះនាងយកដៃទាំងពីរឱបលើកឡើងកាន់វិមាន ដាក់ឲ្យដេកលើទីដេក ក្នុងវេលាដែលនាយសគ្គៈភ្ញាក់ឡើង ក៏ឲ្យភោជនជាទិព្វ រួចឲ្យងូតទឹកក្រអូបជាទិព្វ ឲ្យស្លៀកដណ្តប់សំពត់ជាទិព្វ និងប្រដាប់តាក់តែងដោយគ្រឿងក្រអូប និងផ្កាឈើជាទិព្វ ទើបឲ្យសគ្គគន្ធព្វនោះដេកលើទីដេកជាទិព្វម្តងទៀត ។

ព្រះនាងប្រតិបត្តិគន្ធព្វនោះ អស់ថ្ងៃនោះយ៉ាងនេះ ក្នុងវេលាដែលស្ដេចគ្រុឌត្រឡប់មក ព្រះនាងបានបិទបាំងលាក់គន្ធព្វនោះទុក ហើយក្នុងវេលាដែលស្ដេចគ្រុឌចេញទៅ ព្រះនាងក៏អភិរម្យដោយអំណាចកិលេសតណ្ហាមួយអន្លើដោយគន្ធព្វនោះ ។ ចាប់តាំងអំពីពេលនោះមក ដោយកាលកន្លងទៅកន្លះខែ ពួកពាណិជដែលនៅក្នុងនគរពារាណសីទាំងឡាយ បានមកដល់គល់ដើមជ្រៃ ក្នុងទ្វីបនោះដើម្បីប្រយោជន៍ដល់ការកាន់យកឧសនិងទឹក ។ សគ្គគន្ធព្វក៏ឡើងនាវាជាមួយនឹងពាណិជទាំងនោះ ហើយទៅកាន់នគរពារាណសី និងចូលគាល់ព្រះរាជា ។ ក្នុងវេលាដែលស្ដេចគ្រុឌនោះលេងបាស្កា សគ្គគន្ធព្វបានកាន់យកនូវពិណ កាលធ្វើនូវការដេញនិងច្រៀង ទើបពោលគាថាទី ១ ថា

**វាតិ គន្ធោ តិមិរានំ, កុសមុទ្ទោ ច ឃោសវា;**
**ទូរេ ឥតោ សុយោនន្ទី, តម្ព កាមា តុទន្តិ មំ។**

*ក្លិននៃផ្កាតិមិរព្រឹក្ស រមែងផ្សាយទៅ សមុទ្រដែលពេញដោយទឹក មានសំឡេងគឹកកង បពិត្រស្ដេចតម្ពៈ ព្រោះថា នាងសុយោនន្ទី (នៅ) ក្នុងទីឆ្ងាយពីនគរនេះ កាមទាំងឡាយ តែងចាក់ដោតខ្ញុំ ។*

បណ្ដាបទទាំងនោះ បទថា **តិមិរានំ** បានដល់ ផ្កាតិមិរព្រឹក្ស ។ បានឮមកថា មានតិមិរព្រឹក្សដុះឡោមព័ទ្ធដើមជ្រៃនោះ នាយសគ្គគន្ធព្វពោលយ៉ាងនោះ សំដៅយកតិមិរព្រឹក្សនោះ ។ បទថា **កុសមុទ្ទោ** បានដល់ សមុទ្រតូច ។ បទថា **ឃោសវា** ប្រែថា មានសំឡេងគឹកកង ។ សគ្គគន្ធព្វពោលយ៉ាងនោះ សំដៅយកសមុទ្រដែលនៅជិតដើមជ្រៃនោះ ។ បទថា **ឥតោ** សេចក្ដីថា អំពីនគរនេះ ។ នាយគន្ធព្វហៅព្រះរាជាដោយពាក្យថា **តម្ព** ។ម្យ៉ាងទៀត បទថា **តម្ពកាមា** នេះ លោកសម្ដែងថា កាមដែលព្រះបាទតម្ពរាជទ្រង់ប្រាថ្នា ឈ្មោះថាតម្ពកាមា ។ កាមទាំងឡាយនោះតែងចាក់ដោតនូវខ្ញុំ ។

សុបណ្ណរាជស្ដាប់ពាក្យនោះហើយ ទើបពោលគាថាទី ២ ថា

**កថំ សមុទ្ទមតរិ, កថំ អទ្ទក្ខិ សេទុមំ;**
**កថំ តស្សា ច តុយ្ហញ្ច, អហុ សគ្គ សមាគមោ។**

*អ្នកឆ្លងសមុទ្របាន ដោយប្រការដូចម្តេច អ្នកឃើញកោះឈ្មោះសេទុម ដោយប្រការដូចម្តេច ម្នាលសគ្គៈ ការជួបប្រសព្វនាងសុយោនន្ទីនឹងអ្នក បានមានមកដោយប្រការដូចម្តេច ។*

*បណ្តាបទទាំងនោះ បទថា* **សេទុមំ** *បានដល់ សេទុមទ្វីប ។*

*លំដាប់នោះ នាយសគ្គៈបានពោលគាថាទាំងឡាយ ៣ ថា*

**កុរុកច្ឆា បយាតានំ, វាណិជានំ ធនេសិនំ**
**មករេហិ អភិទា នាវា, ផលកេនាហមប្លវឹ។**

*នាវារបស់ពួកឈ្មួញ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់កុរុកច្ឆៈ បែកធ្លាយដោយមករ ខ្ញុំក៏ឆ្លងសមុទ្រដោយផែនក្តារ ។*

**សា មំ សណ្ហេន មុទុនា, និច្ចំ ចន្ទនគន្ធិនី;**
**អង្កេន ឧទ្ធរី ភទ្ទា, មាតា បុត្តំវ ឱរសំ។**

*នាងសុយោនន្ទីនោះ ជាស្ត្រីមានវាចាទន់ពីរោះ មានក្លិនដូចខ្លឹមចន្ទន៍ អស់កាលជានិច្ច ជាស្ត្រីចម្រើន ស្រង់ខ្ញុំដោយអវយវៈ ដូចមាតាត្រកងនូវបុត្ត ដែលកើតអំពីទ្រូង ។*

**សា មំ អន្នេន បានេន, វត្ថេន សយនេន ច;**
**អត្តនាបិ ច មន្ទក្ខី, ឯវំ តម្ព វិជានហិ។**

*នាងជាស្ត្រីមានភ្នែកទន់ បានផ្គត់ផ្គង់ខ្ញុំ ដោយបាយ ទឹក សំពត់ និងទីដេក ព្រមទាំងខ្លួន បពិត្រស្តេចតម្ពៈ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។*

*បណ្ដាបទទាំងនោះ បទថា* **សា មំ សណ្ហេន មុទុនា** *សេចក្ដីថា ព្រះនាងសុយោនន្ទី កាលត្រាច់ទៅតាមឆ្នេរសមុទ្រ ទ្រង់ឃើញខ្ញុំដែលឡើងប្រាំងដោយផែនក្ដារយ៉ាងនេះហើយ បានលួងលោមខ្ញុំដោយវាចាដ៏ទន់ភ្លន់យ៉ាងពីរោះថា លោកកុំភ័យឡើយ ។ បទថា* **អង្កេន** *សេចក្ដីថា ដៃទាំងគូ លោកពោលថា* **អង្កេន** *ក្នុងទីនេះ ។ បទថា* **ភទ្ទា** *សេចក្ដីថា គួរទស្សនា គួរជាទីជ្រះថ្លា ។ បទថា* **សា មំ អន្នេន** *សេចក្ដីថា ព្រះនាងនោះបម្រើខ្ញុំឲ្យឆ្អែតដោយបាយជាដើម។ បទថា* **អត្តនាបិ ច** *សេចក្ដីថា លោកសម្ដែងថា មិនមែនតែបាយជាដើមប៉ុណ្ណោះទេ ព្រះនាងក៏បានញុំាងឲ្យខ្ញុំឆ្អែត ដោយព្រះនាងអភិរម្យនឹងខ្ញុំដោយខ្លួនរបស់ព្រះនាងទៀត ។ បទថា* **មន្ទក្ខី** *សេចក្ដីថា មានភ្នែកទន់ លោកពោលថា មានការមើលដោយអាការៈទន់ជាប្រក្រតី ។ បាឋៈថា* **មត្តក្ខី** *ដូចនេះក៏មាន អធិប្បាយថា ប្រកបដោយដួងភ្នែក ដូចជា ការស្រវឹង ។ បទថា* **ឯវំ តម្ព** *សេចក្ដីថា បពិត្រព្រះបាទតម្ពរាជ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។*

*កាលនាយគន្ធព្វពោលហើយ ស្ដេចគ្រុឌមានវិប្បដិសារី គិតថា យើងសូម្បីនៅក្នុងសុបណ្ណពិភព ក៏មិនអាចរក្សានាងបាន យើងនឹងជាប្រយោជន៍អ្វី ដោយស្ត្រីទ្រុស្តសីលនោះដូច្នេះហើយ ទើបនាំព្រះនាងសុយោនន្ទីនោះមកថ្វាយព្រះរាជា ហើយក៏ចៀសចេញទៅ ចាប់តាំងពីពេលនោះមក ស្ដេចគ្រុឌក៏លែងត្រឡប់មកនគរពារាណសីនោះទៀត ។*

*ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ឧក្កណ្ឋិតភិក្ខុ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។*

**តទា រាជា អានន្ទោ អហោសិ** *ព្រះរាជាក្នុងកាលនោះ បានមកជា អានន្ទ ។*

**សុបណ្ណរាជា បន អហមេវ អហោសឹ** *ចំណែកសុបណ្ណរាជាគឺតថាគតនេះឯង ។*

*សុយោនន្ទីជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត មណិកុណ្ឌលវគ្គ បិដកលេខ ៥៩ ទំព័រ ១៤)*

*ដោយខេមរ អភិធម្មាវតារ*

*ព.ស.២៥៦១*